# ការគាំទ្រពីគ្រូបង្គោលរបស់រដ្ឋាភិបាលនាំឱ្យមានការផ្លាស់ប្តូរច្រើន នៅក្នុងការគ្រប់គ្រងសាលារៀនក្នុងខេត្តមណ្ឌលគិរី

គណៈកម្មការទ្រទ្រង់សាលារៀនដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលរបស់អង្គការឃែរ ឥឡូវនេះកំពុងខិតខំប្រឹងប្រែងដើម្បីដឹកនាំការសាងសង់ និងរៃអង្គាសប្រាក់នៅសាលារៀនរបស់ពួកគេ។

ចែម សុភ័ក្ត្រ ជាស្ត្រីមមាញឹកម្នាក់។ ក្រៅពីការងារពេញម៉ោងជានាយិកាសាលាបឋមសិក្សា គាត់ក៏ធ្វើជាប្រធានកម្រងសាលារៀនក្នុងស្រុកអូររាំងខេត្តមណ្ឌលគិរី និងជាគ្រូបង្គោលក្នុងក្រុមបំប៉ន និងពិនិត្យតាមដានផងដែរ។ គាត់ពន្យល់ថា នេះគ្រាន់តែជារបៀបដែលគាត់ប្រតិបត្តិការងារប៉ុណ្ណោះ គឺថាគាត់ចូលចិត្តធ្វើឱ្យខ្លួនគាត់រវល់។

ក្នុងនាមជាគ្រូបង្គោល ដែលទទួលបានការបំពាក់បំប៉នចំណេះដឹងតាមរយៈសិក្ខាសាលារបស់អង្គការឃែរកម្ពុជា គាត់ទទួលខុសត្រូវការបង្រៀនសមាជិកគណៈកម្មការទ្រទ្រង់សាលាបឋមសិក្សាអំពីតួនាទី និងការទទួលខុសត្រូវរបស់ពួកគេ។

គាត់និយាយថា ៖ "កាលពីមុនខ្លួនខ្ញុំផ្ទាល់ក៏ធ្លាប់ធ្វើជាសមាជិកគណៈកម្មការទ្រទ្រង់សាលារៀនដែរ តែខ្ញុំមិនដែលដឹងថា អ្វីដែលខ្ញុំត្រូវធ្វើទេ។ គឺទើបតែនៅពេលនៅក្នុងវគ្គបណ្តុះបណ្តាលរបស់អង្គការឃែរប៉ុណ្ណោះទើបខ្ញុំបានដឹងអំពីសេចក្តីណែនាំរបស់ក្រសួងអប់រំ ស្តីពីតួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មការទ្រទ្រង់សាលារៀន"។

សុភ័ក្ត្រ សារភាពថានៅពេលដឹងថាខ្លួននឹងបណ្តុះបណ្តាលក្រុមជនជាតិដើមភាគតិច ដែលក្នុងនោះប្រហែល ៩០%នៃសិក្ខាកាមជាជនជាតិភាគតិច គាត់មានការព្រួយបារម្ភថាគាត់មិនអាចផ្តល់ចំណេះដឹងរបស់គាត់ទៅឱ្យពួកគេបាននោះទេ។

គាត់ធ្លាប់មានការងឿងឆ្ងល់ថា ៖ "ខ្ញុំធ្លាប់មានការព្រួយបារម្ភពីភាពខុសគ្នាផ្នែកវប្បធម៌ និងការអប់រំ។ ចុះបើខ្ញុំមិនអាចធ្វើទំនាក់ទាក់ទំនងជាមួយសមាជិកគណៈកម្មការទ្រទ្រង់សាលារៀនប្រកប ដោយប្រសិទ្ធភាព និងផ្តល់ចំណេះដឹងខ្ញុំទៅឱ្យពួកគេ តើវានឹងទៅជាយ៉ាងណា?"។

គាត់ពន្យល់ថា សំណាងដែរអង្គការឃែរបានបង្រៀនគាត់អំពី "បច្ចេកទេស [ធ្វើការប្រាស្រ័យទាក់ទង] អន្តរវប្បធម៌" ដែលជួយគាត់សម្របសម្រួលសិក្ខាសាលាប្រកបដោយប្រសិទ្ធភាព។

រហូតមកដល់ថ្ងៃនេះគាត់បានសម្របសម្រួលវគ្គបណ្តុះបណ្តាលចំនួន៣នៅតាមសាលារៀនចំនួន១០ ក្នុងស្រុកអូររាំង ខេត្តមណ្ឌលគិរី ដែលគាត់និយាយថា បាននាំឱ្យសហគមន៍មានការចូលរួមក្នុងការគ្រប់គ្រង និងការអភិវឌ្ឍសាលារៀន។

សមិទ្ធផលគួរឱ្យស្ងើចសរសើរមួយដែលគាត់បានឃើញ គឺកើតមាននៅក្នុងសាលាបឋមសិក្សាដើមស្វាយ ដែលស្ថិតនៅក្នុងតំបន់ដាច់ស្រយាល និងពិបាកទៅដល់នៃខេត្តនេះ។


© Nicolas Axelrod / Ruom / CARE

*"គ្រប់គណៈកម្មការទាំងអស់ដែលខ្ញុំបានបណ្តុះបណ្តាលគឺបាននិងកំពុងជួយគាំទ្រសាលារៀនរបស់ពួកគេដោយជោគជ័យនាំឱ្យមានការចូលរួមល្អប្រសើរពីសហគមន៍ ការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងសាលារៀន ព្រមទាំងនាំឱ្យវត្តមានគ្រូ និងសិស្សមានភាពល្អប្រសើរ"។*

សុភ័ក្ត្រនិយាយដោយទឹកមុខញញឹមថា ៖ "ពីមុនគ្មានផ្លូវទៅដល់សាលានេះទេ ដូច្នេះសមាជិកសហគមន៍ត្រូវកាប់ឆ្ការព្រៃដើម្បី ខ្ញុំអាចធ្វើដំណើរទៅធ្វើការបណ្តុះបណ្តាល"។ គាត់បន្ថែមថា៖ "ហើយពេលនោះក៏មិនមែនជាសាលារៀនពិតប្រាកដអីដែរ"។

យោងតាម សុភ័ក្ត្រ បានឱ្យដឹងថាអគារដើមរបស់សាលាបឋមសិក្សាដើមស្វាយស្ថិតក្នុងសភាពទ្រុឌទ្រោម និងពិតជាមិនអាចប្រើប្រាស់បានទេ។ លើសពីនេះទោះបីជាសហគមន៍បានស្នើសុំជំនួយហិរញ្ញវត្ថុពីក្រសួងអប់រំយ៉ាងណាក៏ដោយ ក៏ត្រូវការពេលមួយចំនួនមុនពេលជំនួយនេះធ្លាក់មកដល់សាលារៀន។

សុភ័ក្ត្រនិយាយដោយទឹកមុខមានមោទនភាពថា ៖ "ជំនួសឱ្យការរង់ចាំគណៈកម្មការទ្រទ្រង់សាលារៀន បានធ្វើការរៃអង្គាសប្រាក់ពីសហគមន៍ រួចក៏នាំគ្នាកសាងសាលារៀន"។

នេះមិនមានន័យថា សាលារៀនដទៃទៀតមិនទទួលបានការគាំទ្រពីគណៈកម្មការរបស់ពួកគេនោះទេ។ គាត់គូសបញ្ជាក់ថា ៖ "គ្រប់គណៈកម្មការទាំងអស់ដែលខ្ញុំបានបណ្តុះបណ្តាលគឺបាននិងកំពុងជួយគាំទ្រសាលារៀនរបស់ពួកគេដោយជោគជ័យ នាំឱ្យមានការចូលរួមល្អប្រសើរពីសហគមន៍ ការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងសាលារៀន ព្រមទាំងនាំឱ្យវត្តមានគ្រូ និងសិស្សមានភាពល្អប្រសើរ"។

សុភ័ក្ត្រនិយាយថា ដូច្នេះហើយទើបគាត់ក្លាយជាគ្រូបង្គោល។ [គាត់ពន្យល់ថា]៖ "ខ្ញុំចង់ឱ្យសាលារៀនយើងមានការកែលម្អ និងចង់ធ្វើឱ្យប្រាកដថាសហគមន៍ចូលរួមក្នុងការគ្រប់គ្រងសាលារៀន"។

**These activities are part of the *School Governance* project, which is supported by the Capacity Development Partnership Fund.**

មូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាពវិស័យអប់រំ (CDPF)

*© CARE Cambodia, September 2016*